អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៣៣៩ សរ-១៧ អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៧

# សេចក្តីសម្រេច

## ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា សម្រាប់ការលក់ប្រភពអគ្គិសនីឲ្យក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ៉ែរ ឌីវែឡុបមិន អ្នកធ្វើសេវាកម្មបញ្ជូនរង លក់អគ្គិសនីដុំឲ្យសេវាករចែកចាយនៅខេត្តកំពង់ធំ ត្រង់ចំណុចព្រំប្រទល់ខេត្តសៀមរាប-ខេត្តកំពង់ធំ ព្រំប្រទល់ខេត្តព្រះវិហារ-ខេត្តកំពង់ធំ និងព្រំប្រទល់ខេត្តកំពង់ចាម-ខេត្តកំពង់ធំ

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- បានឃើញប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ ៤២១.រថ.អវថ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៧-២០២០
- យោងអាជ្ញាបណ្ណ លេខ០០១.ឯអ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងលិខិតរបស់អគ្គិសនីកម្ពុជា លេខ ៣៣៣៥.លស.អក.ផយគ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី៣១០ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧

## សម្រេច

**ប្រការ១**

កំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់ **អគ្គិសនីកម្ពុជា** សម្រាប់ការលក់ប្រភពអគ្គិសនីឲ្យ **ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ៉ែរ ឌីវែឡុបមិន** អ្នកធ្វើសេវាកម្មបញ្ជូនរង លក់អគ្គិសនីដុំឲ្យសេវាករចែកចាយនៅខេត្តកំពង់ធំ ត្រង់ចំណុចព្រំប្រទល់ខេត្តសៀមរាប-ខេត្តកំពង់ធំ ព្រំប្រទល់ខេត្តព្រះវិហារ-ខេត្តកំពង់ធំ និងព្រំប្រទល់ខេត្តកំពង់ចាម-ខេត្តកំពង់ធំ តាមលក្ខខណ្ឌ និងអត្រា ដូចខាងក្រោម ៖



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| លក្ខខណ្ឌ | អត្រាថ្លៃលក់ |
|---|---|
| លក់ប្រភពអគ្គិសនីនៅចំណុចព្រំប្រទល់ខេត្តសៀមរាប-ខេត្តកំពង់ធំ និងព្រំប្រទល់ខេត្តព្រះវិហារ-ខេត្តកំពង់ធំ | 0.126 $US / kWh |
| លក់ប្រភពអគ្គិសនីនៅចំណុចអនុស្ថានីយខេត្តកំពង់ចាម-ខេត្តកំពង់ធំ ដោយត្រូវប៉ះប៉ូវការបាត់បង់ថាមពលក្នុងការបញ្ជូនអគ្គិសនីក្នុងចម្ងាយឆ្ងាយលើសពីចំណុចព្រំប្រទល់ខេត្តកំពង់ចាម-ខេត្តកំពង់ធំ (ឃុំសំពោងជ័យ) ចំនួន 8.5% នៃថាមពលដែលបញ្ជូនហួសពីព្រំប្រទល់នេះ ដែលវាស់ដោយនាឡិកាស្ទង់ដាក់នៅចំណុចព្រំប្រទល់ខេត្តកំពង់ចាម-កំពង់ធំ | 0.126 $US / kWh |

## ប្រការ២

ការគណនាថ្លៃលក់ប្រភពអគ្គិសនីសរុបឲ្យក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ចេញពីអនុស្ថានីយកំពង់ចាម តាមប្រការ ១ ខាងលើ ដែលមានលក្ខខណ្ឌជួយប៉ះប៉ូវការបាត់បង់លើថាមពលដែលបានបញ្ជូនហួសពីចំណុចព្រំប្រទល់ខេត្តកំពង់ចាម-ខេត្តកំពង់ធំ ចំនួន 8.5% នៃថាមពលដែលវាស់ដោយនាឡិកាស្ទង់ដាក់នៅចំណុចព្រំប្រទល់ខេត្តកំពង់ចាម-ខេត្តកំពង់ធំ (ឃុំសំពោងជ័យ) ត្រូវគណនាតាមរូបមន្តដូចខាងក្រោម ៖

NC = (M1 - (M2 x CR)) x ER ដែល ៖

NC ៖ ថ្លៃប្រភពថាមពលសរុបដែលត្រូវទូទាត់

M1 ៖ បរិមាណថាមពលចេញពីទ្វារចេញ ២២ kV វាស់ដោយនាឡិកាស្ទង់ដាក់នៅទ្វារចេញនៃអនុស្ថានីយកំពង់ចាម

M2 ៖ បរិមាណថាមពលបញ្ជូនបន្តទៅទៀត វាស់ដោយនាឡិកាស្ទង់ ដាក់នៅព្រំប្រទល់ខេត្តកំពង់ចាម-ខេត្តកំពង់ធំ (ឃុំសំពោងជ័យ)

CR ៖ អត្រាប៉ះប៉ូវការបាត់បង់បរិមាណថាមពលបញ្ជូនបន្ត (8.5% នៃ M2)

ER ៖ អត្រាថ្លៃលក់ (0.126 $US/kWh)

## ប្រការ៣

ក្នុងការទិញអគ្គិសនីពីអគ្គិសនីកម្ពុជា តាមប្រការខាងលើនេះ ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ត្រូវរក្សាមេគុណអានុភាព (cosφ) នៃការទទួលអគ្គិសនីរបស់ខ្លួនឲ្យឋិតនៅក្នុងកម្រិតគុណភាព cosφ ≥ 0.9 ឬ tgφ ≤ 0.484 មានន័យថា ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន មានសិទ្ធប្រើប្រាស់ថាមពលរ៉េអាក់ទីវ ចេញពីប្រព័ន្ធផ្គត់ផ្គង់របស់អគ្គិសនីកម្ពុជា មិនលើសពីចំនួនកំណត់មួយដែលកំណត់ដោយ cosφ ≥ 0.9 ឬ tgφ ≤ 0.484 ។ ក្នុងករណីដែលអតិថិជនខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើប្រាស់ថាមពលរ៉េអាក់ទីវពីប្រព័ន្ធ របស់អគ្គិសនីកម្ពុជាលើសពីចំនួនកំណត់ ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវ ដែលខ្លួនប្រើប្រាស់លើសនេះ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវ ស្មើ នឹង 0.025 $US ក្នុង ១ គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh)។


**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**ប្រការ៤**

អត្រាថ្លៃថ្មីដែលបានកំណត់ខាងលើនេះ ត្រូវអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានលក់ចាប់ពីខួបស្រង់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ ដែលត្រូវនឹងខួបចេញវិក្កយបត្រចាប់ពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៧ តទៅ។ ក្នុងករណីខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន បានចែងនូវ អត្រាថ្លៃខុសពីការកំណត់ក្នុងប្រការខាងលើ អគ្គិសនីកម្ពុជា និងក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ត្រូវធ្វើការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីនៅក្នុងកិច្ចព្រមព្រៀងទិញលក់នោះឡើងវិញជាបន្ទាន់ ដើម្បីអនុវត្តអត្រាថ្លៃលក់អគ្គិសនីឲ្យស្របតាមការកំណត់នៅក្នុងសេចក្តីសម្រេចនេះ ។ ការកែសម្រួលកិច្ចព្រមព្រៀងទិញលក់ឡើងវិញនេះ ប្រសិនបើមាន ត្រូវតែធ្វើយ៉ាងណាឲ្យអត្រាថ្លៃថ្មី អាចអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានលក់ចាប់ពីខួបស្រង់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ តទៅ ។

**ប្រការ៥**

លើកលែងតែការកំណត់ពេលវេលាដែលចែងក្នុងប្រការ ៤ ខាងលើ ខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ដើម្បីអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ បញ្ជីថ្លៃលក់នេះ អាចធ្វើការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីសម្រេចលើថ្លៃលក់អគ្គិសនីចេញមុនទាំងឡាយ ដែលផ្ទុយពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦**

អគ្គិសនីកម្ពុជា និងក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ត្រូវមានភារកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ឲ្យមានប្រសិទ្ធភាព។

**ប្រការ៧**

អគ្គិសនីកម្ពុជា មានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទ ដែលមានការពាក់ព័ន្ធ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

<u>ចម្លងជូន</u> ៖
-ក្រសួងរ៉ែ និងថាមពល
"ដើម្បីជូនជ្រាប"
-អគ្គិសនីកម្ពុជា
-ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន
"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ